ញ៉ុក . ថែម

# មហាវេស្សន្តរជាតក



ភាគទី ១៣

ផ្សាយឡើងវិញ "[illegible]"
រក្សាសិទ្ធិគ្រប់យ៉ាង
ព.ស ២៥៥០ គ.ស ២០០៦

# មហាវេស្សន្តរជាតក

## ទី ១៣

## កណ្ឌនគរកណ្ឌ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

តំ សុត្វា មហាសត្តោ បិតរា សទ្ធឹ សល្លបន្តោ ឥមំ គាថមាហ ។ មហាសត្តោ ឮដំកាលនោះ ព្រះមហាសត្វ សុត្វា បាន ទ្រង់ព្រះសណ្ដាប់ព្រះរាជឱង្ការសម្ដេចព្រះវរមាតាបិតា អារាធនាឱ្យ ស្ដេចលាព្រតចេញអំពីឥសី ចូលទៅគ្រងបុរីរាជធានីដូចដើម ព្រះ អង្គលើកករប្រណម្យសម្ដេចព្រះវររាជមាតាបិតា ក្រាបទូលដោះសា ដោយនូវបាទព្រះគាថាដូច្នេះ ៖

ជម្មេន រជ្ជំ ការេន្តំ រដ្ឋា បព្វាជយិត្ថ មំ
ត្វញ្ច ជានបទា ចេវ នេគមា ច សមាគតាតិ ។

បពិត្រព្រះអង្គជាក្សត្រធំឧត្ដមប្រសើរអើយ ដើមឡើយ ព្រះ អង្គទ្រង់ព្រះមេត្តាប្រោសប្រោណ ព្រះរាជទានឱ្យគ្រងស្វេតច្ឆ័ត្ររដ្ឋរាជ បុរី ឱ្យស្រដីទូន្មានអស់អាណាប្រជារាស្ត្រកូវ ពុំឱ្យធ្វើក្រៅព្រះរាជក្រឹត្យ

Websites: WatKhemaraRatanaram.org or WatKhmers.org

ខុសនឹងព្រះរាជអាជ្ញា ហើយព្រះអង្គថា អស់អាណាប្រជារាស្ត្រទាំងឡាយ សឹងតែក្តៅក្រហាយខឹងនឹងអញខ្ញុំណាស់ ថាត្បិតអញខ្ញុំឱ្យដំរីមង្គល ទៅជាទានឧត្តមជាបរមទាន ទើបគេនាំគ្នាបំបរបង់ឱ្យព្រាត់ប្រាសនិវាស ចាកចោលរាជ្យសម្បត្តិខ្វាត់ចេញមក អញខ្ញុំខំដើរជ្រុលមកនៅនាព្រៃអាយស្មសានឋានស្ងាត់ហើយ បពិត្រអម្ចាស់អើយ ឥឡូវនេះ ព្រះអង្គទ្រង់ព្រះចិន្តាដូចម្តេច ក៏បានជាស្តេចមកអារាធនាអញខ្ញុំដែលព្រះអង្គថាជាអ្នកខុសពុំត្រូវ ឱ្យទៅសោយរាជ្យសម្បត្តិ ដូចអំពីដើមវិញ ខ្ញុំអម្ចាស់ពុំពេញចិត្តឡើយ ។

អណ្តាប់នោះ ព្រះបាទក្រុងស្រីសញ្ជ័យ បានទ្រង់ស្តាប់សេចក្តីនៃព្រះរាជបុត្រ ព្រះមហាវេស្សន្តរបវរខត្តិយាមហាឫសី ព្រះអង្គតបសេចក្តីស្នងព្រះរាជឱង្ការដូច្នោះហើយ ពុំលង់ឡើយ ព្រះអង្គរិះរកបរិហារបណ្តាល ដើម្បីនឹងឱ្យព្រះរាជបុត្រទន់ព្រះទ័យ ទើបមានព្រះបន្ទូលស្ងូត្រនូវបាទព្រះគាថាដូច្នេះ

ទុក្ខជញ្ច ហិ នោ បុត្ត ភូនហច្ចំ កតំ មយា
យោហំ សិវីនំ វចនា បព្វាជេសិំ អទូសកន្តិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បុត្ត ថាហៃកូនស្ងួនតែមួយ ជាត្រួយត្រួលបណ្តូលពន្លក ហឫទ័យបីដូចនយនាមាសឪពុក ហើយហេតុត្បិតបិតានេះធ្វើឱ្យអ្នកមានសេចក្តីអំពល់ទល់ទុក្ខពុំសុខសប្បាយ ចេញមកនៅព្រៃអាយនេះ ព្រោះតែជឿយកពាក្យអ្នកស្រីពិរាស្ត្រវាញុះញង់ ឱ្យបំបរបង់កូនស្ងួនចេញមកនៅភ្នំគិរីវង្កតកំសត់ ៤ អង្គ តាត ហៃកូនស្ងួនសម្លាញ់ឪពុកអើយ ទោសទាំងនេះគួរខុសណាស់ហើយ តាមតែអ្នកអត់ទោសប្រោសបិតា នាកាលគ្រាឥឡូវនេះហោង ។

ព្រះបាទស្រីសញ្ជ័យមានព្រះរាជឱង្ការតែម្ល៉ោះហើយ ព្រះអង្គក៏លើករាជ្យសម្បត្តិថ្វាយព្រះរាជឱរស ហើយមានព្រះបន្ទូលថា ៖

យេន កេនចិ វណ្ណេន          បិតុ ទុក្ខំ ឧទព្វហេ
មាតុយា ភគិនិយាបិ          អបិ បាណេហិ អត្តនោ ។

តស្មា មម ទោសំ ហទយេ អកត្វាន មម វចនំ ករោហិ ឥមំ ឥសិលិង្គំ នីហរិត្វា រាជវេសំ គណ្ហ ។ ម្នាលកូនស្ងួនសម្លាញ់ពេញចិត្ត ស្មើជីវិតនៃព្រះបិតា បើបុគ្គលឯណាកើតមកជាបុរសរ័ត្ន ឥតសង្ស័យនៅនាលោកិយ មានសេចក្តីឧស្សាហ៍ពុំគិតជីវិត កាត់ចិត្ត

ចេញមកជម្រះទុក្ខសោករោគភ័យមន្ទិលក្នុងប្រាណ ។ តស្មា ហេតុនោះ បាកុំបីមានចិត្តខឹងជាគំនុំចងទោសានុទោសផងទាំងឡាយ ចូរធ្វើតាមពាក្យបិតា លាចេញអំពីភេទព្រះតាបស ចូរកូនប្រុសអ្នកទ្រង់គ្រងរាជ្យសម្បត្តិរាជដ្ឋាន តាមបុរាណប្រពៃណី អំពីដើមរៀងមកឱ្យក្សេមក្សាន្ត នឹងបានជាទីពំនាក់នៃព្រាហ្មណ៍ព្រឹទ្ធ បណ្ឌិតកវី មុខមន្ត្រីអាមាត្យ នូវអស់សេវកពលសកលយោធាផង ស្នងបិតានៅនាគ្រានេះឯង ។

សម្ដេចព្រះមហាវេស្សន្តរបវរពុទ្ធង្កុរបណ្ដូលពុទ្ធវង្ស កាលព្រះអង្គនឹងទទួលយករាជ្យសម្បត្តិ តែចាំក្រាបទូលស្នងព្រះរាជឱង្ការសម្ដេចព្រះវរបិតា ឱ្យបានឥតមន្ទិលពិភាល់សង្ស័យ ។ ឯព្រះបាទស្រីសញ្ជ័យ ក៏រមែងជាអង្វរល្ងងលោមពុំឱ្យអាក់អន់ ទើបសម្ដេចព្រះរាជបុត្រទទួលអញ្ជើញតាមព្រះរាជឱង្ការត្រាស់ថា សាធុ! សាធុ! ។

កាលនោះ ឯអស់អាមាត្យទាំង ៦ ម៉ឺន ដែលកើតរួមថ្ងៃជាមួយនឹងព្រះអង្គ លុះបានឮសេចក្ដីថា ព្រះអង្គទទួលអញ្ជើញដូច្នោះហើយ សហជាតអាមាត្យទាំងនោះ លើកករប្រណម្យថ្វាយបង្គំ ព្រះ

បរមរាជាក្រាបទូលថា មហារាជ បពិត្រព្រះអង្គដ៏ទ្រង់នូវគុណាតិរេក ជាឯកលើត្បូងយើងខ្ញុំ អម្ចាស់អើយ អញ្ជើញព្រះអង្គទៅស្រោចស្រង់ នូវទឹកអប់ត្រឡប់នូវគន្ធពិដោរ បន្ទោបង់នូវញើសក្អែល ក្តៅក្រហាយ សប្បាយព្រះអង្គស្រេចហើយ អញ្ជើញស្តេចទទួលយកស្វេតច្ឆ័ត្រ រាជ្យសម្បត្តិ ឋិតនៅជាអម្ចាស់នៃយើងខ្ញុំហោង ។

រីព្រះបរមពោធិសត្វ ខត្តិយវង្សទ្រង់នូវកតិកា ព្រះអង្គទ្រង់ត្រាស់ថា ហៃអាមាត្យទាំងឡាយអើយ ចូរឈប់បន្តិចសិន ។ ទើបស្តេចចូលទៅក្នុងព្រះបរមសាលា ផ្លាស់អស់គ្រឿងព្រះអម្ពរឥសីចេញអំពីព្រះអង្គ ហើយស្តេចទ្រង់ព្រះពស្ត្រព្រះភូសាបរិសុទ្ធប្រដូចនូវពណ៌សង្ខរូច ស្តេចចេញមកគង់នាមុខព្រះអាស្រម ហើយស្តេចធ្វើប្រទក្សិណព្រះបរមសាលា ៣ ជុំ ទើបមានព្រះបន្ទូលថា ឱៈឱ! ព្រះបរមសាលានេះអើយ ជាទីពឹងអាស្រ័យនៃយើងប្រមាណបាន ៩ ខែ និង ១៥ រាត្រី ទើបបានសាងបរមត្ថបារមីសមណធម៌ បានឱ្យសម្តេចព្រះមទ្រី នូវព្រះរាជបុត្រាបុត្រី ទៅជាទានលុះកក្រើកទៅដល់ភវគ្គព្រហ្ម នូវអស់ទេវតាសព្វឋាន ព្រោះត្បិតយើងបានអាស្រ័យបរម

Websites: WatKhemaraRatanaram.org or WatKhmers.org

សាលានេះឯងជាលំនៅ អំពីនេះទៅហើយ សមព្រះបរមសាលានេះនឹងនៅទំនេរ ឥតអ្នកឯណាមួយនៅឡើយ ។ ឱ ! ម្ល៉ែះហើយសត្វទាំងឡាយនឹងមកឃាឃី រីឯព្រះកុដិក៏នឹងស្ងាត់ជ្រងំ ពុំមានអ្នកពិភ័ក្តិរក្សា ម្ល៉េះហើយសមនឹងបាក់ទ្រុឌទ្រោមទៅជាអសារឥតការ ។ ទើបព្រះអង្គលើកព្រះករបវរដាក់លើព្រះកេសវិសេសបង្គំ ដោយបញ្ចង្គប្រតិស្ឋាន នៅខាងមុខព្រះបរមសាលា ហើយព្រះអង្គបិតនៅឋាននេះឯង ។

បពិត្រអើយ ឮដំកាលនោះ មានខ្មាន់ព្រះកេស ចូលទៅក្រាបថ្វាយបង្គំ ហើយចំរើនព្រះកេសាជម្រះព្រះលោមានៃព្រះបរមពោធិសត្វនោះ ។ លុះស្រេចហើយក៏អភិសេកស្រោចស្រង់ ទ្រង់នូវគ្រឿងប្រដាប់សម្រាប់ក្សត្រាល្អរុងរឿង បីដូចជាព្រះឥន្ទ្រាធិរាជសោយរាជ្យសម្បត្តិ បិតនៅនាឋានទេវលោកនាយ ។

តេន វុត្តំ ហេតុនោះ ទើបលោកនាំយកបាលីក្នុងគម្ពីរចរិយាបិដក មកសំដែងថា ៖

តតោ វេស្សន្តរោ រាជា    រជោជល្លំ បវាហយិ

Websites: WatKhemaraRatanaram.org or WatKhmers.org

សព្វំ វត្ថុំ ចជេត្វាន          រាជវេសមធារយីតិ ។

ភោ សារីបុត្ត ហៃធម្មសេនាបតីស្រីសារីបុត្រ កាលនោះ ព្រះបាទស្រីវេស្សន្តរពោធិសត្វ ខត្តិយាធិបតីស្រីសុរិយោវង្សអង្គនា-រាយណ៍នរបតីស្រីសម្មតិទេព មហារាជក្សត្រថ្លៃប្រសើរនោះ លុះព្រះអង្គជម្រះព្រះកេសាស្រេច ស្តេចទ្រង់នូវទឹកអប់ត្រឡប់នីទៅនូវក្រចេះចួងច័ន្ទន៍លំពាន់ក្រស្នា គូរាជេន ឈ្មុសទេសវិសេស សឹងដ៏ល្វេងអប់ត្រឡប់នីទៅនូវគន្ធពិដោរ ស្តេចប្រាសលះលែងនូវគ្រឿងប្រដាប់សម្រាប់ជាអ្នកបួសនោះហើយ ទ្រង់ក៏កាន់យកនូវស្វេតច្ឆ័ត្រ ជាស្តេចប្រកបនូវយសបរិវារជាអធិកពន្លឹកមហិមាក្រៃពេកហោង ។

បពិត្រអើយ ឮដ៏កាលនោះ រីឯព្រះតេជះព្រះយសខ្ពស់វែងឆ្ងាយល្បីឮខ្ចរខ្ចាយសាយសព្វព្រះនគរ បើព្រះអង្គនឹងទតព្រះនេត្រទៅកាន់ទិសឯណានីមួយក្តី ក៏សឹងកក្រើករំពើកញាប់ញ័រដល់ឋាននោះ ព្រោះព្រះអង្គទ្រង់បានបំពេញទានបរមត្ថបារមី ដ៏ក្សេមក្សាន្តក្នុងព្រះហឫទ័យ ។ អស់ទាំងព្រាហ្មណ៍ព្រឹទ្ធ បណ្ឌិតហោរា បុរោហិតព្រមទាំងមុខមន្ត្រីសេនាបតីសេដ្ឋី នាំគ្នាមកជួបជុំសូត្រស្លុតីថ្វាយវុឌ្ឍី

Websites: WatKhemaraRatanaram.org or WatKhmers.org

មង្គលពលីការ នមស្ការចំរើនព្រះពរជ័យថ្វាយព្រះបរមពោធិសត្វស្រេចហើយប្រគំនូវស័ព្ទតូរ្យតន្ត្រី ដ៏មានសូរពន្លឺកគគ្រឹកគគ្រេងមានឧបមាបីដូចរលកនៅកណ្តាលមហាសមុទ្រ ។ អណ្តាប់នោះ នាយដំរីក៏ប្រដាប់គជសារ ដ៏ក្រាលនីទៅនូវកម្រាលដ៏វិចិត្រ ចងនូវដង្គន់ស្នាប់មុខចង្កំភ្លុកកូបហាង លំញ៉ាងដងក្រពាត់ សឹងដ៏ប្រដាប់ដាំត្បូងនិលរ័ត្នមានរស្មីព្រោងព្រាយ នាំចូលទៅថ្វាយព្រះអង្គ ទើបស្តេចទ្រង់នូវព្រះខ័នថ្លា ហើយស្តេចឡើងគង់លើហត្ថីរ័ត្ន ដ៏ធំធាត់មាឧមាំក្លាហាន ។ ឯអស់សេនាជំនិតព្រះអង្គទាំង ៦ ម៉ឺននោះ ក៏មកចោមរោមជាយសបរិវារជុំវិញព្រះអង្គ ។ ស្តេចលីលាទៅគង់ឯព្រះពន្លាជ័យឰដ៏កាលនោះ ។

បពិត្រអើយ ឰដ៏កាលនោះ រីអស់ស្រីរ័ត្នកញ្ញាផងទាំងឡាយក៏នាំគ្នាតាក់តែងព្រះសរីរកាយសម្តេចព្រះនាងមទ្រី ជាអគ្គមហេសីស្រីខត្តិយវង្ស ស្រោចស្រង់ទ្រង់នូវគ្រឿងប្រដាប់សម្រាប់ក្សត្រី អភិសេកជាអគ្គមហេសី ទើបនាំគ្នាសូត្រស្លូតីចំរើនព្រះពរជ័យមង្គលថា សូមព្រះបាទស្រីវេស្សន្តរពិភ័ក្តិរក្សាព្រះម៉ែនាងម្ចាស់ ឱ្យបានសេចក្តីសុខ

Websites: WatKhemaraRatanaram.org or WatKhmers.org

ក្បៀមក្សាន្ត ក្នុងព្រះរាជហឫទ័យ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានបន្ទូលសូត្រសាន្ទូវបាទព្រះគាថាដូច្នេះ ៖

សីសណ្ហាតោ សុចិវត្ថោ សព្វាភរណភូសិតោ
បច្ចយំ នាគមារុយ្ហ ខគ្គំ ពន្ធិ បរន្តបំ ។
តតោ សជ្ជី សហស្សានិ យោធិនោ ចារុទស្សនា
សហជាតា បរិកិរីសុ ននួយន្តា រថេសភំ ។
តតោ មទ្ទីបិ នហាបេសុំ សិវិកញ្ញា សមាគតា
វេស្សន្តរោ តំ ចាលេតុ ជាលី កណ្ហាជិនា ចុភោ
អថោបិ តំ មហារាជា សញ្ចយោ អភិរក្ខតូតិ ។

ភិក្ខវេ ហៃភិក្ខុសង្ឃផងទាំងឡាយអើយ វេស្សន្តរោ រាជារីឯព្រះបាទសម្តេចព្រះវេស្សន្តរបវរខត្តិយសូរ្យវង្ស លុះស្រង់ព្រះសុគន្ធវសស្រេច ទ្រង់ប្រដាប់ព្រះអង្គ ទ្រង់នូវស្នាប់ព្រះឱរ្យ ជើងជរសឹងដ៏ប៉ាក់

Websites: WatKhemaraRatanaram.org or WatKhmers.org

ឆ្នាក់ល្អស្រេចស្រស់ ទើបស្តេចទ្រង់នូវព្រះពស្ត្រ ព្រះភូសាសម្រាប់ក្សត្រ ក្រវាត់នូវជើងបាទ ហើយស្តេចទ្រង់មកុដអារាមរន្ទាម ព្រះសុរងកងកកុណ្ឌលសឹងដ៏ល្អវិចិត្រ ទើបទ្រង់ព្រះទម្រង់ត្បូងនិលវ័ត្នវិចិត្រ នូវពៃទូរ្យសូរ្យកាន្ត ដ៏មានតម្លៃនគរមួយ សម្រាប់រាជាភិសេកជាឯកអគ្គមហាក្សត្រ ទ្រង់នូវគ្រឿងវ័ត្នបញ្ចកកុធភណ្ឌទាំង ៥ ស្រេច ស្តេចគង់លើទៃនមណីរ័ត្ន បាំងនូវស្វេតច្ឆ័ត្រក្លស់ក្លំអភិរម្យ បន្សំនូវអស់គ្រឿងខ្ពស់ ទើបអស់អាមាត្យសេនា ចៅពញាព្រះហ្លួង ឃុនហ្មឺនទាំងពួង នូវអាមាត្យដែលកើតថ្ងៃជាមួយនឹងព្រះអង្គទាំង ៦ ម៉ឺន គាល់ព្រះមហាក្សត្រដោយនូវជួរសង្កាត់ទីទៃ ៗ ។ ឯអង្គព្រះអគ្គមហេសី គឺសម្តេចព្រះមទ្រី ក៏ទ្រង់នូវគ្រឿងប្រដាប់ប្រដា ផ្ទិមអម្ពរសឹងដ៏ល្អឧត្តម ឯអស់ព្រះស្នំក៏សឹងដ៏ស្លៀកដណ្តប់តាមដោយនូវប្រដាប់ទីទៃ ៗ នូវអស់ស្រីអករ៍យាយចាស់ទុំ សឹងវណ្តាប់ដោយនូវកំណាន់ជាពាន់ជាម៉ឺន មាននូវរូបល្អប្រសើរហែសម្តេចព្រះនាងមទ្រី មកអភិសេកជាឯកអគ្គមហេសី ។ ទើបអស់ព្រាហ្មណាចារ្យមកស្រោចស្រង់ព្រះអង្គទាំងពីរ ដោយទឹកស័ង្ខទឹកទង់ដែង អស់ទាំងភ្លេងតូរ្យតន្ត្រីពិណពាទ្យរងំសមនូវសំឡេង

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្គរ គង អស់អាមាត្យមន្ត្រីផង សឹងដំលើកករប្រណម្យក្រាបថ្វាយបង្គំ ថ្វាយព្រះពរ ស្រដីដោយនូវបទព្រះបាលីថាដូច្នេះ វេស្សន្តរោ រាជា ថា សូមឱ្យព្រះបាទស្រីវេស្សន្តរបវរមហាក្សត្រ ចាលេតុ ចូរព្រះអង្គរក្សា សម្តេចព្រះនាងមទ្រី ដ៏ជាព្រះអគ្គមហេសី ឱ្យត្រេអរសាទរស្មោះសរ អភិរម្យ កុំបីមានទុក្ខសោករោគា ឯព្រះជាលីក្រស្នា ក៏សូមឱ្យក្សេម ក្សាន្ត ឱ្យបានថៃរក្សាព្រះវរមាតាបិតា អនាគតកាលទៅឯភ្នែកនោះ ហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ ប្រាកដ បទព្រះបាលីឯណាពុំទាន់ថៃងច្បាស់ លុះព្រះបានត្រាស់ ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រនូវបាទព្រះគាថាដូច្នេះ ៖

ឥទញ្ច បច្ចយំ លទ្ធា បុព្វេ កិលេសមត្តនោ
អានន្ទិយំ អចារីសុ រម្មណីយេ គិរិព្វជេ ។
ឥទញ្ច បច្ចយំ លទ្ធា បុព្វេ កិលេសមត្តនោ
អានន្ទចិត្តា សុមនា បុត្តេ សង្គម្ម លក្ខណា ។
ឥទញ្ច បច្ចយំ លទ្ធា បុព្វេ កិលេសមត្តនោ

Websites: WatKhemaraRatanaram.org or WatKhmers.org

អានន្ទចិត្តា បីតិតា          សហ បុត្តេហិ លក្ខណាតិ

ហៃភិក្ខុអើយ កាលនោះ ព្រះបាទស្រីវេស្សន្តរ នូវព្រះនាងមទ្រី កាលណាបើបានជួបប្រសព្វនឹងព្រះរាជបុត្រទាំងពីរ មួយអន្លើនឹងអស់រេហ៍ពលផងទាំងឡាយជាបច្ច័យហើយ មានព្រះរាជហឫទ័យត្រេកអរសោមនស្សា ទ្រង់ភ្លឹករលឹកទៅដល់សេចក្ដីលំបាកវេទនាអំពីមុន កាលស្ដេចនៅក្នុងព្រៃព្រឹក្សានោះ ទើបស្ដេចមានព្រះរាជឱង្ការ ឱ្យនាំយកស្គរអានន្ទភេរីទៅទូងទូទាំងសព្វចក្រព្រៃភ្នំក្រំថ្ម ផ្សាយពត៌មានឱ្យមហាជនបានដឹងថា ទ្រង់ប្រោសព្រះមេត្តាឱ្យអ្នករាល់គ្នាលេងល្បែងមហោស្រពសព្វតំបន់ ជាទីក្សេមក្សាន្តសប្បាយតាមប្រាថ្នា ។ ឯសម្ដេចព្រះនាងមទ្រី ដ៏ទ្រង់នូវលក្ខណាល្អពិសី កាលព្រះនាងបានជួបជុំព្រះរាជបុត្រាបុត្រីទាំងពីរហើយ ក៏មានព្រះទ័យត្រេក-អរសោមនស្សា ទើបព្រះនាងមានព្រះសវនីយ៍ ទៅនឹងព្រះរាជបុត្រទាំងពីរដោយនូវបាទព្រះគាថាដូច្នេះ ៖

ឯកភត្តី បុរេ អាសឹ          និច្ចំ ថណ្ឌិលសាយិនី
ឥតិ មេតំ វតំ អាសិ          តុម្ហំ កាមា ហិ បុត្តកា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

តំ មេ វតំ សមិទ្ធជ្ជ    តុម្ហេ សង្គម្ម បុត្តកា
មាតុជំបិ តំ ចាលេតុ    បតុជំបិ ច បុត្តកា
អថោបិ តំ មហារាជា    សញ្ជយោ អភិរក្ខតុ
យង្កិញ្ចិត្ថិ កតំ បុញ្ញំ    មយ្ហញ្ចេវ បិតុច្ច តេ
សព្វេន តេន កុសលេន    អជរោ ត្វំ អមរោ ភវាតិ ។

បុត្តកា ថាហៃនាងក្រស្នាបាជាលី កូនស្ងួនសំឡាញ់ម្ដាយទាំងពីរអើយ កូនអើយ នាកាលម្ដាយព្រាត់ព្រាកចាកចេញពីស្រុក ម្ដាយដើរជជ្រុលជជ្រកមកនៅព្រៃ ក៏ប្រស្រ័យតែឃើញមុខកូនស្ងួនសំឡាញ់ទាំងពីរ រីទុក្ខទាំងឡាយនោះមិញ ក៏អន្តរធានបាត់ទៅ កូនអើយ ម្ដាយតាំងចិត្តស្វែងរកផលាដ៏ជាអាហារទាំងឡាយ ឯការ ម្ដាយដើរតែម្នាក់ឯងពុំក្រែងជីវិត គិតប្រាថ្នាតែយកមកចិញ្ចឹមកូនគួកំសត់ក្រែងអត់ឃ្លាន ម្ដាយថ្នមពុំឱ្យមានហ្មងប៉ងបានជាគួកំសត់នៅក្នុងព្រៃ។ ឱហេតុតែកម្មវិបាកអ្វីអើយ ក៏ឱ្យព្រាត់ព្រាកចាកកូនសង្សារ អំពីកាលព្រះបិតាអ្នក ឱ្យទៅជាទានជូនជកព្រាហ្មណ៍ព្រឹទ្ធាចារ្យទទួលយក

Websites: WatKhemaraRatanaram.org or WatKhmers.org

បាទៅ ម្ដាយនេះតែងនៅជាទុក្ខខ្លោចផ្សា ពុំមានស្រាកស្រាន្ត រីអស់ផលាហារ ក៏ពុំបានបរិភោគា្ដ តែងតែសោកាទូញយំឥតស្បើយ ។ លុះវេលាល្ងាចហើយម្ដាយគិតដល់អ្នកទាំងពីរ ដល់ម្ដាយពុំយល់មុខ ទុក្ខក៏កើតឡើងជាថ្មី ម្ដាយដេកនៅដីផ្ទាល់ប្រឹថពី រីឯក្ដីស្រឡាញ់នៃជននីនូវព្រះវរបិតានោះពន់ប្រមាណ ត្បិតបានពិភ័ក្តិរក្សាកូនសំឡាញ់ រីសម្ដេចព្រះអយ្យកោព្រះអយ្យិកានោះមិញ ក៏មានព្រះរាជហឫទ័យសោមនស្សា នឹងព្រះរាជនត្តានត្តាពុំឱ្យហ្មង ។ ប្រការមួយសោតរីកុសលផលបុណ្យ នៃព្រះវររាជមាតាបិតា នូវអ្នកទាំងពីរបានធ្វើប៉ុន្មាន ៗ ក្ដី សូមឱ្យជួយពិភ័ក្តិរក្សាបា កុំបីមានព្យាធិរោគាជរាមកបៀតបៀនបាបានឡើយ ហើយឱ្យបាបានស្នងគ្រងព្រះនគរតាងព្រះវរបិតានោះតទៅ ។

បពិត្រអើយ ឰដ៏កាលនោះ ព្រះនាងសុបារសុប្បតីទេវីទ្រង់មានព្រះតម្រិះក្នុងព្រះចិន្តាថា តាំងអំពីថ្ងៃនេះតទៅ ព្រះនាងមទ្រីដ៏ជាព្រះសុណិសាកូនប្រសាអញ ទ្រង់ព្រះភូសានិងប្រដាប់តាក់តែងអាត្មា ដោយគ្រឿងអលង្ការ ដ៏ត្រកាលទាំងពួងនេះ លុះព្រះនាងទ្រង់

ព្រះចិន្តាដូច្នេះហើយ ក៏ឱ្យចាត់ចែងរណ្តាប់គ្រឿងអលង្ការ ទុកក្នុងស្មុគ្រ រួចហើយនៃ ទើបចាត់បញ្ជូនទៅព្រះរាជទានព្រះនាងមទ្រី ប្រយោជន៍ ដើម្បីនឹងឱ្យទ្រង់ជាប្រដាប់សម្រាប់អាត្មាព្រះអង្គនាង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ ហើយ ព្រះអង្គមានព្រះបន្ទូលស្ងួត្រសាន្ទវបាទព្រះគាថាដូច្នេះ ៖

កប្បាសិកញ្ច កោសេយ្យំ ខោមកោទុម្ពរានិ ច
សស្សុ សុណ្ហាយ ចាហាសិ យេហិ មទ្ទី អសោភថ ។
តតោ ខោមញ្ច កាយូរំ គីវេយ្យំ រតនាមយំ
សស្សុ សុណ្ហាយ ចាហាសិ យេហិ មទ្ទី អសោភថ ។
តតោ ខោមញ្ច កាយូរំ អង្គទំ មណិមេខលំ
សស្សុ សុណ្ហាយ ចាហាសិ យេហិ មទ្ទី អសោភថ ។
ឧណ្ណតំ មុខផុល្លញ្ច នានារត្តេ ច មាណិយេ
សស្សុ សុណ្ហាយ ចាហាសិ យេហិ មទ្ទី អសោភថ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ឧក្កត្ថំ កិង្កមតាំ　　មេខលំ បដិចាទុតាំ
សស្សុ សុណ្ហាយ ចាហោសិ　　យេហិ មទ្ទី អសោភថ ។
សុត្តញ្ច សុត្តវជ្ជញ្ច　　ឧបនិជ្ឈាយ សេយ្យសិ
អសោភថ រាជបុត្តី　　ទេវកញ្ញាវ នន្ទនេ ។
សីសណ្ហាតា សុចិវត្ថា　　សព្វាភរណភូសិតា
អសោភថ រាជបុត្តី　　តាវត្តឹសាវ អច្ឆរា ។
កទលីវ វាតច្ឆុបិតា　　ជាតា ចិត្តលតាវនេ
ទន្តាវរណាសម្បន្នា　　រាជបុត្តី អសោភថ ។
សកុណី មានុសិនីវ　　ជាតា ចិត្តប្បត្តា បតិ
និគ្រោធបក្កពិម្ពោដ្ឋី　　រាជបុត្តី អសោភថាតិ ។

ភិក្ខវេ ហៃភិក្ខុសង្ឃដ៏ទ្រង់ព្រតដោយនូវគន្លងធម៌ តតោ អណ្តាប់នោះ ព្រះនាងសុបារសុប្បតី ទ្រង់គិតក្នុងព្រះរាជហឫទ័យថា សម្តេចព្រះនាងមទ្រីដ៏ជាព្រះរាជបុត្រីស្រីសុណិសា លាព្រតចេញអំពីតាបសឫសីហើយ ក៏ព្រះនាងនឹងទ្រង់គ្រឿងប្រដាប់សម្រាប់ព្រះ

Websites: WatKhemaraRatanaram.org or WatKhmers.org

អគ្គមហេសី ទើបស្តេចព្រះនាងសុបារសុប្បតី យកគ្រឿងទាំងឡាយឱ្យសម្តេចព្រះសុណិសា គឺព្រះពស្ត្រកាសិកពស្ត្រ នូវព្រះពស្ត្រកោទុម្ពរពស្ត្រ កោសេយ្យពស្ត្រ ខោមពស្ត្រ ដ៏ល្អបរិសុទ្ធ គិតដ៏អ្នកប៉ាក់ឆ្នាក់នីទៅនូវល្វេសមាសជាជរសឹងដ៏ស្រស់ស្រេច សម្តេចព្រះនាងសុបារ-សុប្បតី រើសផ្ទង់បម្រុងព្រះរាជទាន ។ ប្រការមួយសោត សម្តេចព្រះនាងមទ្រី ដែលបានលាព្រតចេញអំពីតាបសឫសី ជាអគ្គមហេសីឧត្តមសមជានឹងទ្រង់អស់គ្រឿងប្រដាប់សម្រាប់ឱ្យគួរជាអគ្គមហេសី ទើបសម្តេចព្រះនាងសុបារសុប្បតី ព្រះរាជទានជាដើមគឺ មកុដអារាមរន្ទាមព្រះសុរងកងព្រះហ្វូរ័ក ត្រសាល់ស្ទៀតសក់ ស្នាប់ទ្រាប់ព្រះជង្ឃចិញ្ចៀនព្រះទម្រង់សឹងដ៏ដាំនូវត្បូងបុស្សរបទុមរាគវ័ត្ន មុក្តាវ័តប្រពាលវ័ត្ន សឹងដ៏មានរស្មីនោះច្រវ៉ាត់ស្មើរនឹងស្រក ព្រះសុពណ៌បាទុក៏សឹងដ៏មានរចនា ទាំងសុគន្ធមាលាក្រចេះចូងចន្ទន៍លំពាន់ពុំសែន គួរាជេនឈ្មុសទេស សឹងដ៏ជាគ្រឿងវិសេសសម្រាប់ទ្រង់ ។ សម្តេចព្រះនាងសុបារសុប្បតី សឹងផ្ទង់ព្រះរាជទានសម្តេចព្រះនាងមទ្រីនោះឯងហោង ។ ទើបសម្តេចព្រះនាងមទ្រី ស្រីសុភលក្ខណា ទទួលអស់

Websites: WatKhemaraRatanaram.org or WatKhmers.org

គ្រឿងប្រដាប់ប្រដា មកទ្រង់ប្រដាប់ព្រះអង្គ ល្អបវរដូចស្រីទេពអប្សរ បវរកញ្ញា ឋិតនៅនាត្រៃត្រិង្សាសួគ៌ឋាន ដ៏មានដងខ្លួននោះភ្លៀវភ្លំ រៀវម្ងល បីដូចបណ្តូលចេកមាស អភិភាសកើតឮដ៏ព្រៃចិត្តលតាវ័ន គិតដ៏ត្រូវខ្យល់មណ្ឌវាត បោកបក់ទន់ទោរទៅវិញទៅមក មានប្រការដូចម្តេចមិញ ។ រីសម្តេចព្រះនាងមទ្រី ក៏មានលំអដូច្នោះ រីព្រះទន្តទាំង ៤០ នោះ រាងញឹកញាប់ដូចអ្នកប្រដាប់នីទៅនូវពេជ្ររ័ត្ន ដ៏មានផ្ទូរព្រះឱស្ឋនោះញញឹមប្រិមប្រិយ ល្អបីដូចផ្លែជ្រៃមាសបាសទុំ សមនូវកំពស់ទ្រង់ទ្រាយប្រពៃ បីដូចស្រីសួគ៌ មុខគួរឱ្យពិតពិលរមិលមើលក្រៃពេក ។

តស្សា ច ជាតមានេសុំ ជាតិរុឡ្សំវ កុញ្ជរំ
សត្តិក្ខមំ សរក្ខមំ ឦសាទន្តំ ឧរូឡ្ហវំ
សា មទ្ទី ជាតមារុហិ ជាតិរុឡ្សំវ កុញ្ជរំ
សត្តិក្ខមំ សរក្ខមំ ឦសាទន្តំ ឧរូឡ្ហវន្តិ ។

កាលនោះ នាយហត្ថីក៏នាំដំរីធំធាត់ឧទារល្អបវរ មានភ្លុកស្តាំនោះ ទន្ទាំដូចចន្ទោលរាជរថ មានចិត្តទាហានហ៊ានក្លានឹងសឹក

Websites: WatKhemaraRatanaram.org or WatKhmers.org

ពុំភ្លឹកនូវកាំភ្លើងថ្មើងកណ្តាលរឿណរង្គ សឹងដ៏ប្រដាប់ផ្ទង់ដោយគ្រឿងចងកញ្ចោងមាសល្អឧត្តម នាំមកថ្វាយសម្តេចព្រះនាងមទ្រីស្រីរ័ត្នកញ្ញា ទើបព្រះនាងលីលាឡើងគង់លើព្រះទីនាំងគជសារ ។ ឯអស់ស្រីជាបរិវារ ក៏សឹងដ៏ព្រមចិត្តមិត្តមូល ខ្លះក្រាបពិតទូលញញឹមប្រិមប្រិយ ខ្លះលើកដៃថ្វាយបង្គំ សមនូវរូបនោះល្អល្អះគាប់គួរ ខ្លះក៏សើចស្រួលផ្អៀងផ្អង ខ្លះដើរញ៉ៀងញ៉ង ផ្សារស្រីហែសម្តេចព្រះនាងមទ្រីក្សត្រីមកឯទ័ពចំណាតស្រេច ។ ស្តេចទាំងពីរព្រះអង្គមានព្រះទ័យសោមនស្សា នឹងអស់បរិវារនោះច្រើនពន់ប្រមាណ នៅឋានចំណាតនោះឯង ។ រីឯព្រះបាទស្រីសញ្ជ័យដ៏ជាសម្តេចព្រះវរបិតា លុះបានអភិសេកសម្តេចព្រះឱរសាស្រេច ស្តេចមានព្រះទ័យនោះ ត្រេកអរសាទរពន់ប្រមាណ ទើបស្តេចចេញទៅប្រពាតព្រៃព្រឹក្សា នឹងអស់ពពួកសេនាទាហានប្រមាណ ១២ អក្ខោភិនី នូវអស់ស្រីព្រះស្នំទ្រង់ទតអស់ភ្នំនូវរុក្ខជាតិទាំងឡាយ ខ្លះទើបរំសាយកេសរផ្កា ខ្លះដុះសែមកែមលើគ្នាមានផ្លែសឹងដ៏ទុំ ៗ ឯអស់ស្រីព្រះស្នំ ក៏សឹងរត់ដណ្តើមគ្នាបេះប្រឡេះលេងជាផាសុកសប្បាយទីទៃ ៗ ទើបស្តេចចេញមកពីព្រៃនោះ

ឡើងទៅលើភ្នំជាសប្បាយលោះលាយក្នុងព្រះរាជហឫទ័យ នឹងអស់ព្រៃព្រះហិមពាន្ត សឹងដ៏មានបក្សាបក្សីបញ្ចុកចំណីកូនវា ខ្លះក៏ស្រែកដោយភាសារងំ ខ្លះក៏ទំយំទ្រូពករកគូវា សឹងដ៏មានសំឡេងនោះពីរោះ ៗ ឯអស់អ្នកដង្ហែទាំងនោះ ក៏សឹងត្រេកអរសោមនស្សា ផ្ទៀងត្រចៀកស្ដាប់សព្វសត្វទាំងឡាយ សឹងដ៏មានតម្រេកចិត្ត ទើបស្ដេចទតសត្វម្រឹគីម្រឹគា ប្រើស ទ្រាយ ទន្សាយ ទន្សោង ខ្លោង គោព្រៃច្រើនក្រៃពន់ប្រមាណ ទើបបានព្រះអង្គទតឧទកធារា ដោយនាចក្រជ្រោះចន្លោះភ្នំ សឹងដ៏មានផ្កាបទុមច្រាសច្រាលដេរដាស សឹងដ៏ដុះឆ្លូកឆ្លាស់ដោយពណ៌ទីទៃ ៗ ឧត្បល ចង្កុលណី លំចង់ ស្បុង្គជ សឹងដ៏ដុះលាយលេចគ្នាទាំង ៥ ពណ៌ដ៏រហង់ ៗ ។ ឯអស់ស្រីផងក៏ត្រេកអរពន់ប្រមាណ ខ្លះបេះបានផ្កា ខ្លះបេះផ្លែមកផី ជាសប្បាយសឹងអស់ស្រីព្រះស្នំទាំងឡាយ នៅឋាននោះឯង ។

ក៏ហេតុតែតេជះព្រះមេត្តាបារមី នៃព្រះបរមពោធិសត្វបណ្ដាលឱ្យពួកម្រឹគសាហាវ មានរាជសីហ៍និងខ្លាធំជាដើម ព្រមទាំងបក្សីបក្សានៅនាព្រៃព្រះហិមពាន្ត មិនចេះបៀតបៀនគ្នាទៅវិញទៅ

Websites: WatKhemaraRatanaram.org or WatKhmers.org

មកដល់តិចឡើយ តែងមានចិត្តអាណិតស្រឡាញ់គ្នាទៅវិញទៅ មកហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថៃងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាន្ទវបាទព្រះគាថាដូច្នេះ ៖

សព្វម្ហិ តំ អរញ្ញម្ហិ　　　　យាវន្តេត្ថ មិគា អហុ
វេស្សន្តរស្ស តេជេន　　　　ជាញ្ញមញ្ញំ វិហេឋយុំ។
សព្វម្ហិ តំ អរញ្ញម្ហិ　　　　យាវន្តេត្ថ ទិជា អហុ
វេស្សន្តរស្ស តេជន　　　　ជាញ្ញមញ្ញំ វិហេឋយុំ ។
សព្វម្ហិ តំ អរញ្ញម្ហិ　　　　យាវន្តេត្ថ មិគា អហុ ។

ឯកជ្ឈំ សន្និចាតឹសុ

វេស្សន្តរេ បយាតម្ហិ　　　　សិវីនំ រដ្ឋវឌ្ឍនេ ។
សព្វម្ហិ តំ អរញ្ញម្ហិ　　　　យាវន្តេត្ថ ទិជា អហុ

ឯកជ្ឈំ សន្និចាតឹសុ

Websites: WatKhemaraRatanaram.org or WatKhmers.org

វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។

សព្វម្ហិ តំ អរញ្ញម្ហិ យាវន្តេត្ថ មិគា អហុ

ជាស្ស មញ្ជូនិ កុជីសុ

វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។

សព្វម្ហិ តំ អរញ្ញមិ យាវន្តេត្ថ ជិជា អហុ

ជាស្ស មញ្ជូនិ កុជីសុ

វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេតិ ។

ភិក្ខវេ ហៃភិក្ខុសង្ឃផងទាំងឡាយ ដ៏ទ្រង់នូវព្រតក្នុងបវរពុទ្ធសាសនា រីសត្វម្រឹគា រាជសីហ៍ គជសីហ៍ រមាំង រមាស ប្រើស ទ្រាយ ទន្សាយ ទន្សោង ឈ្លូសផង ឯសារពើសត្វចតុប្បាទ គឺគជសារ គោ គោ សិង្ហ សីហ៍ មហិង្សា ខ្លា អស្សមុខី យក្ខិនី ខ្មោចព្រាយ សារពើសត្វទាំងឡាយនៅក្នុងព្រៃ នូវសារពើបក្សីបក្សា មយូរា រាជហង្ស ក្រៀល ចង្រៀលខ្សង ត្រយង ត្រុំ ត្លុម ស្ទាំង ភូវាំង អុកអក លលកទទា នូវអស់ម្រឹគីម្រឹគាប៉ុន្មាន ៗ ក្តី អម្បាលអាស្រ័យនៅខាងមាត់ចង្វាត់អាស្រមនៃព្រះបរមពោធិសត្វ សឹងដ៏មានចិត្តស្រឡាញ់គ្នា ពុំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ហ៊ានពាធាបៀតបៀនឱ្យហេតុជាមន្ទិលដូចកាលអំពីមុន ហេតុតេជះបុណ្យជាត្រកាលព្រះរាជសម្ភារ នៃព្រះបាទស្រីវេស្សន្តរនោះឯង ។

អណ្តាប់នោះសារពើសត្វ ដឹងសេចក្តីព្រះរាជឫសី ស្តេចនឹងត្រឡប់ចូលទៅព្រះនគរវិញ ។ អស់សត្វអម្បាលនៅក្នុងព្រៃព្រះហិមពាន្ត ក៏សឹងមកជួបជុំពុំបានឃំរងាវទ្រពករកគ្នា សឹងព្រួយចិត្តជាទុក្ខទំនៅស្ងួតស្ងប់ស្ងោរស្ងប់ ស្ទើរពុំមានជីវិតគិតថា ឱអំពីដើមបានព្រះបាទស្រីវេស្សន្តរបវររាជឫសី ព្រះអង្គមានព្រះមេត្រីករុណា គ្រងរក្សាយើងទាំងឡាយ សឹងជាសុខក្សេមក្សាន្ត ពុំមានបៀតបៀនគ្នាឡើយ ។ ឱ ! អំពីនេះទៅហើយ តើនឹងបានអ្នកឯណាជាទីពឹងអាស្រ័យ នៃសារពើសត្វបក្សាបក្សី ដូចនៃព្រះមហាវេស្សន្តរ បវរពោធិសត្វនោះ ឥតអង្គីមានឡើយ ។

**សញ្ជយោ នរិន្ទោ** រីឯព្រះបាទស្រីសញ្ជ័យបរមបពិត្រជាមកុដលើត្បូងអស់អ្នកស្រីពិរាស្ត្រផង **តីឡិត្វា** ព្រះអង្គស្តេចប្រពាតនៅក្នុងព្រៃព្រះហិមពាន្ត ជាសុខក្សេមក្សាន្តប្រមាណមួយខែហើយទើបមានព្រះរាជឱង្ការ ឱ្យហៅអស់មុខមន្ត្រី សេនាបតីដ៏ជាធំមក

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយមានព្រះរាជឱង្ការថា ហៃអស់អ្នកទាំងឡាយអើយ ភជាមគ្គោ រីអស់ផ្លូវទាំងឡាយដែលសម្តេចព្រះវេស្សន្តរ បវរពោធិសត្វរាជបុត្រនៃយើង អ្នកនឹងចូលទៅថ្កានព្រះនគរបវររាជដ្ឋានសឹងដ៏ឆ្ងាយ តើអ្នកទាំងឡាយប្រុងប្រៀបរៀបប្រដាប់ប្រដា ស្រេចបរិបូណ៌ហើយឬនៅឡើយទេ ចូរអ្នកទាំងឡាយប្រាប់អញឱ្យបានដឹង ក្នុងកាលឥឡូវនេះឯង ។

អស់មុខមន្ត្រីសេនាបតីទាំងនោះ លុះបានស្តាប់ព្រះរាជឱង្ការដូច្នេះហើយ ក្រាបថ្វាយបង្គំទូលថា ទេវ បពិត្រសម្តេចព្រះនរិន្ទ្រនរនាថនារាយណ៍នរបតីស្រីសម្មតិទេព មហាក្សត្រថ្លៃប្រសើរអើយ មគ្គោ រីឯមាគ៌ានោះ យើងខ្ញុំជាខ្ញុំល្អងធូលីព្រះបាទ រៀបប្រដាប់ប្រដាស្រេច អញ្ជើញស្តេចត្រឡប់ចូលទៅព្រះនគរវិញ បានតាមសព្វព្រះរាជហឫទ័យ ។

អណ្តាប់នោះ ព្រះបាទក្រុងស្រីសញ្ជ័យ ព្រះអង្គបានជ្រាបសេចក្តីដូច្នោះហើយ ពុំលង់ឡើយស្តេចឱ្យអញ្ជើញព្រះរាជបុត្រាបុត្រីនូវព្រះចៅទាំងពីរហើយ ព្រះអង្គឱ្យយកស្គរជ័យភេរី វាយប្រាមប្រាប់

Websites: WatKhemaraRatanaram.org or WatKhmers.org

អស់រេហ៍ពលសកលយោធា សេនាទាហានឱ្យបានសឹងគ្រប់គ្នាថា ស្តេចលើកព្យុហៈយាត្រាចេញពីព្រៃថ្កានព្រះនគរពិជ័យជេតុត្តរ ទើបព្រះបាទសម្តេចព្រះវេស្សន្តរ ស្តេចព្រះរាជដំណើរទៅជាមួយនឹងរាជបរិវារយ៉ាងធំសម្បើមណែនណាន់តាន់តាប់បើនឹងរាប់ជារយៈផ្លូវតាំងពីភ្នំគិរីវង្កតដរាបដល់ក្រុងពិជ័យជេតុត្តរនោះ ជាចម្ងាយ ៦០ យោជន៍។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថៃងច្បាស់ លុះព្រះអង្គបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាន្ទូវបាទព្រះគាថាដូច្នេះ ៖

បដិយត្តា រាជមគ្គា     វិចិត្តា បុប្ផសន្ថតា
វសិ វេស្សន្តរោ រាជា     យត្ថ យាវ ជេតុត្តរា ។
តតោ សដ្ឋី សហស្សានិ     យោធិនោ ចារុទស្សនា
សមន្តា បរិកិរឹសុ
វេស្សន្តរេ បយាតម្ហិ     សិវិរំ រដ្ឋវឌ្ឍនេ ។
ឱរោធា ច កុមារា ច     វេសិយានា ច ព្រាហ្មណា
សមន្តា បរិកិរឹសុ

Websites: WatKhemaraRatanaram.org or WatKhmers.org

វេស្សន្តរេ បយាតម្ហិ    សិវីនំ រដ្ឋវឌ្ឍនេ ។

ហត្ថារោហា អនីកដ្ឋា    រថិកា បត្តិការកា

សមន្តា បរិកិរឹសុ ។

វេស្សន្តរេ បយាតម្ហិ    សិវីនំ រដ្ឋវឌ្ឍនេ ។

សមាគតា ជានបទា    នេគមា ច សមាគតា

សមន្តា បរិកិរឹសុ ។

វេស្សន្តរេ បយាតម្ហិ    សិវីនំ រដ្ឋវឌ្ឍនេ ។

កាពោជិយោ ជម្មជរា    ឥន្ទិហត្ថា សុរម្មិកា

បុរតោ បដិបជ្ជឹសុ

វេស្សន្តរេ បយាតម្ហិ    សិវីនំ រដ្ឋវឌ្ឍនេ ។

ភិក្ខវេ ហៃភិក្ខុផងទាំងឡាយអើយ រាជមគ្គោ វិមាគ៌ា ដែលស្តេចព្រះរាជដំណើរនោះ ពួកប្រជាជននាំគ្នាជួយតាក់តែង ឱ្យបានរាបទាបស្មើល្អប្រពៃ ប្រដាប់ប្រដាដោយដើមចេក ក្អមទឹកអធិកនីទៅនូវដោយទង់ជ័យរាជវតិឆត្រផ្កាក្រងចងរំយោល មានក្លិនពិដោរ

Websites: WatKhemaraRatanaram.org or WatKhmers.org

សព្វទិសារហូតរយៈផ្លូវ ៦០ យោជន៍ តាំងពីភ្នំគិរីវង្កតដែលស្តេចប្រថាប់ ដរាបដល់ជេតុត្តរនគររាជបុរី ។

លុះបានឫក្សពារពេលាល្អ ទើបសម្តេចក្សត្រាក្សត្រីទាំង ៦ ព្រះអង្គ ស្តេចឡើងគង់លើគជសារ អស់ទាំងពួកសេនាអាមាត្យសហជាតទាំង ៦ ម៉ឺន ក៏ប្រដាប់តាក់តែងរាងកាយ ដ៏ល្អរុងរឿងដោយគ្រឿងមាស ដៃកាន់ផ្ទុស្នានូវគ្រឿងសព្វយុទ្ធ មានចិត្តមោះមុតក្លាហានតាមហែព្រះបាទស្រីវេស្សន្តរបរមក្សត្ររៀបជាជួរជាសង្កាត់ ដោយនូវចង្វាត់ទីទៃ ៗ នៅសងខាងមាគ៌ានោះ ដើម្បីដង្ហែស្តេចថ្កានព្រះនគរ តបន្ទាប់មក ពួកស្រីព្រះស្នំ ព្រះរាជកុមារ ព្រះញាតិវង្សានុវង្ស នូវពួកបុត្រអាមាត្យ បន្ទាប់មកទៀត ដល់ពួកឈ្មួញគហបតី នូវពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យ ទើបដល់ទៅពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើងសឹងនាំគ្នាចោមរោមហែហមតាមស្តេច ។ ពួកសេនាទាហានមានកាយពាក់សុទ្ធតែគ្រឿងក្រោះសំណាញ់ ក្បាលពាក់មួកទង់ដែង ដៃកាន់ខែលដាវលំពែង ជាក្បួនហែនាំមុខ ។ ចំណែកខាងប្រជាជនអ្នកស្រុកអ្នកនិគម នូវអ្នកជនបទដែលតាមហែហមព្រះបាទស្រីសញ្ជ័យ ក៏ដើរ

Websites: WatKhemaraRatanaram.org or WatKhmers.org

ហែតាមក្បួនក្រោយ ដោយលំដាប់គ្នាមក ទើបមានព្រះរាជឱង្ការ ឱ្យលើកចតុរង្គសេនាយាត្រាតាមរាជមាគ៌ា ដែលបានរៀបចំបំរុងទុកនោះឯង ។ កាលនោះ ព្រះបាទស្រីវេស្សន្តរបវរពោធិសត្វខត្តិយវង្ស នូវព្រះបាទក្រុងស្រីសញ្ជ័យ នូវព្រះនាងសុបារសុប្បតីរាជទេវី ព្រះរាជបុត្រាបុត្រី នូវសម្តេចព្រះសុណិសា ស្តេចលីលាយាត្រាទៅ ក្នុងមួយថ្ងៃបានចម្ងាយ ១ យោជន៍ ត្រូវជា ៦០ យោជន៍ជាប្រាកដ កំណត់បាន ២ ខែ ទើបស្តេចបានដល់ពិជ័យជេតុត្តរបវររាជដ្ឋាននោះឯងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលថា ៖

តេ ចារីសុ បុរំ រម្មំ ពហុធាការតោរណំ
ឧបេតំ អន្នបានេហិ នច្ចគីតេហិ ចូភយំ ។
វិត្ថា ជានបទា អាសុំ នេគមា ច សមាគតា
អនុប្បត្តេ កុមារម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ចេលុក្ខោចោ បវត្តិត្ថ　　　អាគតេ ជេជាយកេ
ជន្ទិប្បវេសិ នគរេ　　　ពន្ធជា មោក្ខោ អយោសថាតិ ។

ភិក្ខវេ ហៃភិក្ខុផងទាំងឡាយអើយ រីក្សត្រទាំង ៦ អង្គ ស្តេចចូលទៅដល់ក្រុងពិជ័យជេតុត្តរ ចូលក្នុងព្រះនគរដ៏ក្សេមក្សាន្ត សប្បាយពុំមានជាទុក្ខ ។ ស្តេចឡើងគង់លើប្រាសាទដ៏ប្រសើរស្អាងស្អាត ហើយស្តេចទតព្រះនគររមិលមើលទៅព្រះនគរ នូវអស់ជហ្វាដងក្តារខ្លោងទ្វារនាងច្រាល អម្បាលដែលជាងរចនា សឹងដ៏ល្អវិចិត្រដ៏មានប្រការនោះផ្សេង ៗ រីក្នុងព្រះនគរនោះសោត គិតដ៏អ្នកប្រដាប់នីទៅនូវភោជនាហារ មានរសពិសាផ្សេង ៗ ហើយមានល្បែងច្រៀងរាំ នូវរបាំផងទាំងឡាយសឹងមានច្រើន ព្រះអង្គទតទៅយល់ហើយមានព្រះរាជហឫទ័យសោមនស្សសាទរ រីអស់នគរតូចធំ និគមស្រុកក្រៅលំនៅជនបទ នាកាលស្តេចព្រះបាទស្រីវេស្សន្តរបវរពុទ្ធវង្សស្តេចចូលមកដល់ក្នុងព្រះនគរហើយ រីអស់មហាជនផងទាំងឡាយសឹងដ៏មានចិត្តនោះ ត្រេកអរសាទររួសរាយ នាំដង្វាយស្ងួយរែមកថ្វាយព្រះមហាបុរសរ័ត្នវិសេសនោះច្រើនក្រៃពេក ។ រីព្រះបរពោធិសត្វ

Websites: WatKhemaraRatanaram.org or WatKhmers.org

នោះសោត ព្រះអង្គឱ្យទូងនូវភេរីក្នុងព្រះនគរ ប្រាមប្រាប់បង្គាប់អស់អាណាប្រជារាស្ត្រផងទាំងឡាយ ឱ្យស្រាយខ្នោះដោះឃ្នាងច្រូលច្រវាក់ អន្ទាក់ណែងណងអស់ទាំងចំណងសត្វផងទាំងឡាយ កុំបីឱ្យមាននៅក្នុងព្រះនគរនោះឡើយ ។

កាលនោះ ព្រះបរមពោធិសត្វ ស្តេចចូលក្រឡាព្រះបន្ទំបរមសុខ សួស្តីក្នុងរាត្រីហៀបនឹងព្រឹកព្រាងស្វាងព្រះសុរិយា ទើបស្តេចទ្រង់ព្រះចិន្តានឹកក្នុងព្រះរាជហឫទ័យថា ឱថ្ងៃព្រឹកនេះ សមស្នូមផងទាំងឡាយ វាឮពត៌មានថាអញបានមកដល់ព្រះនគរហើយ សមព្រហាមស្អែកនេះឯង វានឹងមកចោមរោមសុំអញពុំខាន បើដូច្នេះ តើអញនឹងបានទ្រព្យអ្វីឱ្យទានស្នូមផងទាំងឡាយនោះ ។ នាកាលព្រះអង្គទ្រង់ព្រះតម្រិះដូច្នោះហើយ ក៏ក្តៅទៅដល់អាសនៈសម្តេចអមរិន្ទ្រាធិរាជ ព្រះអង្គអាចគិតពិចារណា ជ្រាបសភាពដោយព្រះទិព្វយោបល់នូវប្រការអម្បាលនោះហើយ ពុំយូរឡើយព្រះអង្គបណ្តាល នូវមហាមេឃឯង ឱ្យជោរជន់នូវទឹក បង្អុរនូវភ្លៀងរ័ត្នទាំង ៧ ប្រការ ឱ្យធ្លាក់ចុះមកឯលិច ឯកើត ឯជើង ឯត្បូង ព្រះរាជមន្ទីរនោះ ប្រមាណស្មើចង្កេះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទីក្រៅអំពីនោះប្រមាណស្មើជង្គង់ ។

បុនទិវសេ លុះព្រឹកឡើងហើយ ព្រះអង្គឱ្យអាមាត្យទៅប្រាមប្រាប់អស់មនុស្សម្នាមហាជនទាំងឡាយថា ទ្រព្យធ្លាក់ចុះត្រង់ផ្ទះសម្រាប់របងរបស់បុគ្គលឯណា ក៏ឱ្យបុគ្គលនោះជញ្ជូនយកទុកជាទ្រព្យរបស់ខ្លួនចុះ ។ បើធ្លាក់ក្នុងឋានពុំមានម្ចាស់ ព្រះអង្គឱ្យកើបជញ្ជូនយកមកគរទុកក្នុងព្រះឃ្លាំង ព្រះអង្គបានទ្រង់ព្រះរាជសទ្ធាធ្វើបុណ្យ ឱ្យទានដរាបលុះដល់កំណត់អស់ព្រះជន្មទិវង្គតទៅ ។

តមត្ថំ បកាសេន្តោ សត្ថា អហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលនូវបាទព្រះគាថាដូច្នេះ ៖

ជាតរូបមយំ វស្សំ ទេវោ ចាវស្សិ តាវទេ
វេស្សន្តរេ បរិជ្ជម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
តតោ វេស្សន្តរោ រាជា ទានំ ទត្វាន ខត្តិយោ
កាយស្ស ភេទា សប្បញ្ញោ សគ្គំ សោ ឧបបជ្ជថាតិ ។

ភិក្ខវេ ម្នាលសង្ឃដ៏ខ្លាចភ័យក្នុងវដ្តសំសារ វេស្សន្តរេ នា

Websites: WatKhemaraRatanaram.org or WatKhmers.org

កាលព្រះបាទស្រីវេស្សន្តរបវរខត្តិយវង្ស តែងទ្រង់ធ្វើសេចក្តីចំរើនដល់ពួកអ្នកស្រីពិរាស្រ្ត លុះស្តេចចូលដល់ព្រះនគររាជបុរី សម្តេចអមរិន្ទ្រកោសីយ៍ ក៏ទ្រង់បង្អុរនូវភ្លៀងរ័ត្នទាំង ៧ ប្រការ ឱ្យធ្លាក់ចុះមកក្នុងព្រះរាជធានីមួយរំពេច ។ កាលនោះ ព្រះបាទស្រីវេស្សន្តរបរមក្សត្រ ទ្រង់មានព្រះប្រាជ្ញាដ៏ប្រសើរឧត្តម តែងទ្រង់អប់រំបន្ទំទានបារមី រៀងរាបដរាបដល់អស់ព្រះជន្មទិវង្គតទៅ ។ ព្រះអង្គក៏បានទៅកើតនៅនាតុសិតសួគ៌ាទេវលោកនាយ បានជាទេវបុត្រ ១ ព្រះអង្គទ្រង់ព្រះនាមករណ៍បវរថា **សន្តុសិតទេវបុត្រ** ប្រាកដហោង ។

*សត្ថា* រីព្រះអរហំសម្មាសម្ពុទ្ធស្ស ដ៏ជាមកុដឥស្សរកំពូលត្រៃភព *អាហរិត្វា* លុះព្រះអង្គនាំនិទាន ព្រះធម៌វិសេសទេសនាមហាវេស្សន្តរជាតក ដ៏ប្រដាប់ប្រដានីទៅនូវគាថាមួយពាន់ ទើបព្រះអង្គមានព្រះពុទ្ធដីកាថា **ភិក្ខវេ** ហៃភិក្ខុសង្ឃផងទាំងឡាយ **មហាមេ-ឃោ** រីមហាមេឃបណ្តាលនូវភ្លៀងបោក្ខរព័ស៌ជាអស្ចារ្យ ធ្លាក់ចុះមកក្នុងសមាគមនៃព្រះញាតិតថាគតនោះ ពុំតែឥឡូវនេះឡើយ ភិក្ខុអើយ អំពីដើមមក កាលដែលតថាគតនៅជាព្រះបាទស្រីវេស្សន្តរ

Websites: WatKhemaraRatanaram.org or WatKhmers.org

នោះ ក៏មានភ្លៀងបោក្ខរព័ស៌ធ្លាក់ចុះមកដូច្នេះដែរ ។ លុះទ្រង់សម្តែងនូវចតុរារិយសច្ចធម៌ចប់ស្រេចហើយ រីអស់មនុស្សម្នាមហាជនផងទាំងពួង ក៏បានលុះសោតា សកិទា អនាគា អរហាត្តនោះច្រើនពន់ប្រមាណ ទើបព្រះអង្គជំនុំប្រជុំជាតកថា ៖

តទា ជូជកោ ទេវទត្តោ រីជូជកព្រាហ្មណ៍ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាទេវទត្ត ។

អមិត្តតាបនា ព្រាហ្មណី ចិញ្ចាមាណវិកា រីនាងអមិត្តតាបនា ជាប្រពន្ធជូជកព្រាហ្មណ៍នោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជានាងចិញ្ចាមាណវិកា ។

ចេតបុត្តោ ឆន្នោ រីឯចេត្តបុតតែងជាអ្នកចាំទ្វារផ្លូវព្រះបរមពោធិសត្វនោះមិញ លុះក្រឡាប់ជាតិចេរវិលវឹងមកបានជាមហាឆន្ន ។

អច្ចុត្តតាបសោ សារីបុត្តោ រីអច្ចុត្តមហាឫសី តែងនឹងបង្ហាញផ្លូវជូជកព្រាហ្មណ៍ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាមហាសារីបុត្រ ។

សក្កោ អនុរុទ្ធោ រីសម្តេចអមរេន្ទ្រាធិរាជ តែងនឹងឱ្យឱវាទ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដំបូន្មានព្រះបរមពោធិសត្វ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាអនុរុទ្ធាចារ្យ ។

វិស្សុកម្មោ ច មោគ្គល្លានោ ព្រះវិស្សុកម្មទេវបុត្រដែលនិម្មិតព្រះអាស្រមថ្វាយ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាមហាមោគ្គល្លាន ។

មគ្គរុទ្ធិ សីហោ ឧបាលិ រីទេវតាដែលនិម្មិតអាត្មាជារាជសីហ៍ ចាំរាំងរាផ្លូវព្រះនាងមទ្រីនោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាព្រះឧបាលី ។

ព្យគ្ឃរាជា សីវលិ រីឯទេវតាដែលនិម្មិតអាត្មាជាខ្លាធំ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាព្រះសីវលិ ។

ទិបិ ច មុល្លិជាតោ រីឯទេវតាដែលនិម្មិតជាខ្លាដំបង ចាំពាំងរាំងផ្លូវព្រះនាងមទ្រី លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាមុល្លនាគ។

ទេវោ កច្ចាយនោ រីទេវបុត្រដែលនិម្មិតជាព្រះវេស្សន្តរទៅស្រាយចំណងចៅជាលីនោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាមហាកច្ចាយនៈ ។

ទេវធីតា វិសាខា ពុទ្ធុបាសិកា រីនាងទេពធិតាដែល និម្មិតជាព្រះនាងមទ្រី ទៅស្រាយចំណងនាងក្រស្នា លុះក្រឡាប់ជាតិចេរវិលវឹងមក បានជានាងវិសាខាពុទ្ធុបាសិកា ។

បច្ចយជាតោ វារណោ កស្សបោ សំឃរុឡោ រីឯដំរី បច្ច័យនាគេន្ទ្រនោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាមហា-កស្សបសង្ឃព្រឹទ្ធាចារ្យ ។

ករេណុកា កិសាគោតមី រីឯមេដំរី លុះក្រឡាប់ជាតិចេរវិលវឹងមក បានជានាងកិសាគោតាមី ។

មទ្ទរាជា មហានាមោ រីឯព្រះបាទមទ្ទរាជ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាមហានាម ។

អត្ថុន្តរោ មហាមច្ចោ អានន្ទោ ពុទ្ធុបដ្ឋាកោ រីឯមហា-មាត្យ ដែលប្រដាប់ប្រដាទានថ្វាយព្រះបរមពោធិសត្វនោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាអានន្ទ ។

ធានវេយ្យាវច្ចាមច្ចោ អជាថបិណ្ឌិកុបាសកោ រីអាមាត្យ ដែលជាអ្នកខ្វល់ខ្វាយ ក្នុងការបរិច្ចាគទានថ្វាយព្រះបរមពោធិសត្វ

Websites: WatKhemaraRatanaram.org or WatKhmers.org

នោះ លុះក្រឡាប់ជាតិចេរវិលវឹងមកបានជាអនាថបណ្ឌិកឧបាសក ។

សញ្ជយនរិន្ទោ សុទ្ធោទនមហារាជា រីព្រះបាទស្រីសញ្ជ័យនរិន្ទរាជនោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាព្រះបាទស្រីសុទ្ធោទនមហារាជពុទ្ធបិតា ។

ផុស្សតី ទេវី សិរិមហាមាយា រីនាងសុបារសុប្បតីទេវី ដ៏ជាព្រះវររាជមាតាព្រះបរមពោធិសត្វ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាព្រះនាងសិរិមហាមាយាពុទ្ធមាតា ។

មទ្ទី ទេវី យសោធរា រាហុលមាតា រីព្រះនាងមទ្រីទេវី ដ៏ជាព្រះវររាជមាតាចៅជាលីនិងនាងក្រស្នា លុះក្រឡាប់ជាតិចេរវិលវឹងមក បានជានាងយសោធរារាហុលមាតា ។

ជាលិកុមារោ រាហុលោ រីចៅជាលីកុមារនោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជារាហុលកុមារ ។

កណ្ហាជិនា ឧប្បលវណ្ណា រីនាងក្រស្នារាជកញ្ញា លុះក្រឡាប់ជាតិចេរវិលវឹងមក បានជានាងឧប្បលវណ្ណា ។

សេសបរិសា ពុទ្ធបរិសា រីបរិស័ទសំណល់សល់លែងអំពី

Websites: WatKhemaraRatanaram.org or WatKhmers.org

នោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាបរិស័ទរបស់តថាគត ។

វេស្សន្តរោ មហារាជា បង អហមេវ សម្មាសម្ពុទ្ធោ រីព្រះបាទស្រីវេស្សន្តរមហារាជនោះ មិនគឺអ្នកដទៃឡើយ អហមេវ គឺអង្គអញតថាគតហ្នឹងឯង ដ៏បានត្រាស់ប្រាជ្ញាសព្វេញ្ញូតាញាណ ជាទីពំនាក់នៃសត្វលោកផងទាំងឡាយ ។

វេស្សន្តរជាតកំ ហៃសាធុសប្បុរសផងទាំងឡាយអើយ ថាបើបុរសបុគ្គលឯណា បានស្តាប់ត្រាប់ត្រងរងរសអាថ៌ធម៌វិសេសទេសនា មហាវេស្សន្តរជាតកនេះហើយ ក៏សឹងរំដោះប្រាសចាកទុក្ខសោករោគភ័យ ចង្រៃឧបទ្រព្យផងទាំងឡាយ ទោះនៅក្នុងលោកិយក៏ប្រសើរ លុះអនាគតកាលទៅឯភ្នែកក៏សឹងបានលុះសោតា សកិទា អនាគា អរហត្តផល បានដល់សម្បត្តិព្រះនិព្វាន ដ៏ជាឋានបរមសុខក្សេមក្សាន្ត ប្រសើរនោះទៀងប្រាកដហោង ។

ឯតរភាណ្ណំ និដ្ឋិតំ បពិត្រអើយ អាត្មាភាពសម្តែងថ្លែងព្រះធម៌វិសេសទេសនាមហាជាតក កណ្ឌគរកណ្ឌ ដ៏ប្រដាប់ប្រដា

នូវគាថា ៨៨ គាថា ក៏ចូរជាបច្ច័យនៃទាយក ឧបាសក ឧបាសិកា ចប់ជាសូរេចបរិបូណ៌សមគួរដោយនូវវេលានេះឯងហោង ។ល។

(ចប់នគរកណ្ឌ ទី ១៣ តែប៉ុណ្ណេះ)

---

វាយខំព្យូទ័រសាឡើងវិញ

ដោយ

**ភិក្ខុ កិច្ចកិរតោ ឡាយ រិន**

និង

ត្រួតពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ

ដោយ

**លោកគ្រូ ធម្មនាថ ផនប្រសិទ្ធី**

ដើម្បីផ្សព្វផ្សាយ ជូនជាធម្មទាន តាមវិបសាយ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានឈ្នះអស់ទានទាំងពួង

Websites: WatKhemaraRatanaram.org or WatKhmers.org




Websites: WatKhemaraRatanaram.org or WatKhmers.org